# បទបង្ហាញ

# ស្តីពី

# អាជ្ញាធរជាតិដោះស្រាយវិវាទ
# ក្រៅប្រព័ន្ធតុលាការ

រៀបចំដោយ ៖

នាយកដ្ឋានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់
នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# មាតិកា

១. អំពីការបង្កើត **អ.ជ.ក.**

២. កិច្ចដំណើរការការងាររបស់ **អ.ជ.ក.**

  ២.១. កិច្ចដំណើរការរបស់ **អ.ជ.ក.**

  ២.២. សមាសភាព តួនាទី និងភារកិច្ចរបស់ **អ.ជ.ក.**

  ២.៣. អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.**

  ២.៤. មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ (**ម.ស.វ**)

៣. កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ **អ.ជ.ក.**

  ៣.១. យន្តការទទួលពាក្យបណ្ដឹង

  ៣.២. ការអនុវត្តមុខងាររបស់ **ម.ស.វ.** ៖ សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ

  ៣.៣. កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទរបស់ **អ.ជ.ក.**

  ៣.៤. ការដាក់ពាក្យប្ដឹងទៅសាលាដំបូងជំទាស់នឹងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ

# ១. អំពីការបង្កើត អ.ដ.ក

❖ **អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.)** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣។

❖ **អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក.)** គឺជាយន្តការស្ថាប័នថ្នាក់ជាតិ បំពេញបន្ថែមឱ្យប្រព័ន្ធដោះស្រាយវិវាទដែលមានស្រាប់នៅព្រះរាជាណាចក្រកម្ពុជា ដែលមានបេសកកម្មដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ។

# ១. អំពីការបង្កើត អ.ជ.ក

**ចក្ខុវិស័យ ៖** លើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពឆាប់រហ័សនៃការដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ។

**គោលបំណង ៖**

- ជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះក្តី
- បង្កើតសេវាដោះស្រាយវិវាទឱ្យកាន់តែទៅកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន
- ធានាបាននូវភាពសុខដុមរមនា និងយុត្តិធម៌ក្នុងសង្គមជាតិ

# ២. កិច្ចដំណើរការការងាររបស់ អ.ដ.ក.

## ២. ១. កិច្ចដំណើរការរបស់ អ.ដ.ក.

អ.ដ.ក.

**អគ្គលេខាធិការដ្ឋាន**



**មន្ត្រី និងក្រុម សម្រុះសម្រួល ដោះស្រាយវិវាទ**




- កិច្ចប្រជុំរៀងរាល់ត្រីមាស ឬតាមការចាំបាច់
- មានសញ្ញាសម្គាល់ផ្ទាល់
- មានត្រាប្រើប្រាស់ផ្ទាល់
- មានឯកសណ្ឋានបំពេញការងារ
- ប្រើប្រាស់ថវិការដ្ឋ និងប្រភពស្របច្បាប់

# ២. កិច្ចដំណើរការការងាររបស់ អ.ជ.ក.

## ២. ២. សមាសភាព តួនាទី និងភារកិច្ចរបស់ អ.ជ.ក.

### ២.២.១. សមាសភាព (មាត្រា៣)

❖ សមាសភាពរបស់ **អ.ជ.ក.** រួមមាន ៖

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី | ជាប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអធិការកិច្ច | ជាអនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាអនុប្រធានប្រចាំការ |

- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី, ក្រសួងពាណិជ្ជកម្ម, ក្រសួងកិច្ចការនារី, ក្រសួងធម្មការ និងសាសនា, គណៈ-មេធាវីនៃព្រះរាជាណាចក្រកម្ពុជា, ក្រុមប្រឹក្សានីតិកម្មនិងយុត្តិធម៌នៃក្រសួងយុត្តិធម៌ និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ជាសមាជិក។

❖ **អ.ជ.ក.** អាចមានសមាសភាពបន្ថែមពីតំណាងក្រសួង-ស្ថាប័នផ្សេងទៀត ឬជ្រើសរើសចេញពីឥស្សរជនដែលមានបទពិសោធក្នុងកិច្ចការដោះស្រាយវិវាទ ឬជំនាញផ្នែកកិច្ចការច្បាប់ តុលាការ ឬកិច្ចការសង្គម។

# ២. កិច្ចដំណើរការការងាររបស់ អ.ដ.ក.

## ២.២.២. តួនាទី និងភារកិច្ចចម្បងរបស់ អ.ដ.ក. (មាត្រា៤)

- ដឹកនាំ សម្របសម្រួល និងអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការសម្រុះសម្រួលផ្សះផ្សាវិវាទ
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ណែនាំ វិធានការនានា និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ដាក់ចេញនូវក្រមសីលធម៌ ក្រមប្រតិបត្តិ វិធាន និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់អនុវត្តការសម្រុះសម្រួលផ្សះផ្សាវិវាទ
- ទទួលដោះស្រាយពាក្យបណ្ដឹងនានាដែលស្នើសុំឱ្យសម្រុះសម្រួលផ្សះផ្សាវិវាទក្រៅប្រព័ន្ធតុលាការ
- រៀបចំយន្តការចុះពិនិត្យ និងដោះស្រាយក្រៅប្រព័ន្ធតុលាការនូវវិវាទ ឬបណ្ដឹងនៅតាមមូលដ្ឋាន

# ២. កិច្ចដំណើរការការងាររបស់ អ.ជ.ក.

## ២.៣. អគ្គលេខាធិការដ្ឋាននៃ អ.ជ.ក.

- ❖ អគ្គលេខាធិការដ្ឋាន បំពេញតួនាទីជាសេនាធិការឱ្យ **អ.ជ.ក.** លើកិច្ចការរដ្ឋបាល កិច្ចការហិរញ្ញវត្ថុ និងកិច្ចការបច្ចេកទេស។
- ❖ អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការ ១ រូប និងមានអគ្គលេខាធិការរងមួយចំនួន។
- ❖ អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ក.** ៖
  - ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្តីស្នើសុំពីប្រធាន **អ.ជ.ក.**
  - ជ្រើសរើសចេញពីឥស្សរជន ឬមន្ត្រីរាជការ ដែលមានបទពិសោធបម្រើការងារផ្នែកច្បាប់ រដ្ឋបាល ឬ ហិរញ្ញវត្ថុ រយៈពេលយ៉ាងតិច ៥ ឆ្នាំ។
- ❖ មន្ត្រីបំពេញការងារនៅអគ្គលេខាធិការដ្ឋាន គឺជាមន្ត្រីរាជការក្របខ័ណ្ឌនៃក្រសួងយុត្តិធម៌ ឬក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងអាចមានមន្ត្រីកិច្ចសន្យាតាមការចាំបាច់។

# ២. កិច្ចដំណើរការការងាររបស់ អ.ជ.ក.

## ២.៤. មន្ត្រីសម្រុះសម្រួលដោះស្រាយវិវាទ (ម.ស.វ.) (មាត្រា១០)



ម.ស.វ.

| | |
|---|---|
| **សមាសភាព** | ជ្រើសរើសចេញពីក្នុងចំណោមមន្ត្រីរាជការក្របខ័ណ្ឌ ឬចេញពីក្នុងចំណោមសារការី មេធាវី និងអ្នកប្រកបវិជ្ជាជីវៈច្បាប់ផ្សេងទៀត ឬបុគ្គលផ្សេងទៀត ដែលមានជំនាញផ្នែកច្បាប់ ឬជំនាញពាក់ព័ន្ធនឹងការដោះស្រាយវិវាទ |
| **ការជ្រើសរើស** | **ដំណាក់កាលទី១៖** ការដាក់ពាក្យ និងការជ្រើសរើស |
| | **ដំណាក់កាលទី២៖** ត្រូវឆ្លងកាត់ការបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយក្រសួងយុត្តិធម៌ |
| | **ដំណាក់កាលទី៣៖** ត្រូវទទួលបាននីតិសម្បទាពី **អ.ជ.ក.** |
| **ការធ្វើសច្ចាប្រណិធាន** | ត្រូវធ្វើសច្ចាប្រណិធានដែលរៀបចំដោយក្រសួងយុត្តិធម៌ មុននឹងអនុវត្តមុខងាររបស់ខ្លួន |
| **ប្រាក់ឧបត្ថម្ភ** | អាចទទួលបានប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភក្នុងការបំពេញការងាររបស់ខ្លួន។ |

# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក.

## ៣.១. យន្តការទទួលពាក្យបណ្ដឹង



# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក.

## ៣.១. យន្តការទទួលពាក្យបណ្តឹង (ត)

❖ ប្រភេទនៃវិវាទដែលអាចសម្រុះសម្រួលផ្សះផ្សាដោយ **អ.ជ.ក.** ៖

- វិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម និងវិវាទដទៃទៀត ដែលផ្អែកតាមច្បាប់ ការបញ្ចប់វិវាទទាំងនោះចំណុះឱ្យសេរីភាពនៃឆន្ទៈរបស់ភាគី។
- មិនអាចធ្វើបានឡើយចំពោះបទល្មើសព្រហ្មទណ្ឌ លើកលែងតែច្បាប់អនុញ្ញាត។

❖ ការដាក់ពាក្យបណ្តឹង ឬការបញ្ជូនសំណុំរឿងវិវាទជូន **អ.ជ.ក.** ធ្វើការសម្រុះសម្រួលផ្សះផ្សា៖

- បុគ្គលដែលអាចដាក់ពាក្យបណ្តឹង: រូបវន្តបុគ្គល ឬនីតិបុគ្គល (ដោយផ្ទាល់ ឬតាមរយៈស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ឬ
- សំណុំរឿងបញ្ជូនពីសាលាជម្រះក្តី ក្នុងករណីភាគីវិវាទណាមួយបង្ហាញឆន្ទៈឱ្យធ្វើការសម្រុះសម្រួល។

# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ដ.ក.

## ៣.២. ការអនុវត្តមុខងាររបស់ ម.ស.វ. ៖ សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវ

**សិទ្ធិរបស់ ម.ស.វ៖**




- អាចស្នើសុំកិច្ចសហការពីស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ ក្នុងការចុះពិនិត្យ និងដោះស្រាយនូវវិវាទ ឬបណ្តឹងនានានៅតាមមូលដ្ឋាន តាមរយៈការសម្រុះសម្រួលផ្សះផ្សា។
- អាចកោះអញ្ជើញភាគីវិវាទ សាក្សី ឬបុគ្គលពាក់ព័ន្ធ។
- អាចណែនាំភាគីវិវាទឱ្យបញ្ជាក់ពីការទាមទារ ឬផ្តល់ព័ត៌មានបន្ថែម តាមការចាំបាច់។
- អាចចុះស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងវិវាទ តាមការចាំបាច់។
- អាចផ្តល់មតិពាក់ព័ន្ធនឹងវិវាទ ឬស្នើនូវដំណោះស្រាយក្នុងការបញ្ចប់វិវាទ។

# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក.

## ៣.២.ការអនុវត្តមុខងាររបស់ ម.ស.វ. ៖ សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវ

**ភារកិច្ចរបស់ ម.ស.វ៖**




- មិនត្រូវធ្វើការសម្រេចសេចក្ដីលើរឿងវិវាទ ជំនួសភាគីវិវាទ។
- ត្រូវគោរពតាមឆន្ទៈយល់ព្រមដោយសេរី និងដោយស្ម័គ្រចិត្តរបស់ភាគីវិវាទ។
- ត្រូវផ្ដល់យោបល់អំពីផលវិបាកដែលអាចកើតមានពីការព្រមព្រៀងបញ្ចប់វិវាទ។
- ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងក្រមប្រតិបត្តិដែលកំណត់ដោយ **អ.ជ.ក.**។
- នៅពេលចុះអនុវត្តការងារ **ម.ស.វ.** ឬក្រុមការងារសម្រុះសម្រួលដោះស្រាយវិវាទនៃ **អ.ជ.ក.** ត្រូវមានលិខិតបញ្ជាបេសកកម្ម និងប្រើប្រាស់ឯកសណ្ឋានផ្លូវការ។

# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក.

## ៣.២.ការអនុវត្តមុខងាររបស់ ម.ស.វ. ៖ សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវ

**ការទទួលខុសត្រូវរបស់ ម.ស.វ៖**




- ក្នុងការអនុវត្តមុខងាររបស់ខ្លួន **ម.ស.វ.** ដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភបំពាន ក្នុងចេតនាទុច្ចរិតធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវតាមច្បាប់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។
- ប៉ុន្តែ **ម.ស.វ.** មិនទទួលខុសត្រូវនោះទេ ចំពោះការអនុវត្តមុខងារដែលខ្លួនបានធ្វើ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក.

## ៣.៣. កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទរបស់ អ.ជ.ក.

ក្នុងករណីភាគីវិវាទព្រមព្រៀងសះជាបញ្ចប់វិវាទ **ម.ស.វ.** ត្រូវចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ។ បន្ទាប់ពីការចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ អាចមានករណី ២ ដូចខាងក្រោម ៖

- ករណីមានការប្ដឹងតវ៉ាចំពោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ៖ ភាគីវិវាទមានសិទ្ធិប្ដឹងតវ៉ាទៅ **អ.ជ.ក.** ក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃធ្វើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ប្រសិនបើកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទធ្វើឡើងដោយមិនត្រឹមត្រូវស្របតាមព្រះរាជក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។ **អ.ជ.ក.** ត្រូវពិនិត្យ និងដោះស្រាយលើពាក្យប្ដឹងតវ៉ានោះ។
- ករណីមិនមានការប្ដឹងតវ៉ាចំពោះកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ឬការប្ដឹងតវ៉ាត្រូវបានបដិសេធ៖ កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទត្រូវចាត់ទុកថាបានធ្វើឡើងដោយត្រឹមត្រូវ និងមាន (១)- តម្លៃគតិយុត្តដូចលិខិតយថាភូត (២)- ត្រូវទុកជាបន្ទាល់ដែលតុលាការត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ និង(៣)- មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពររបស់តុលាការ និងត្រូវចាត់ទុកជាលិខិតអនុវត្ត។ ក្នុងករណីនេះ **ម.ស.វ.** ឬ **អ.ជ.ក.** ដែលចេញកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ត្រូវផ្ដល់រូបមន្តអនុវត្តតាមការស្នើសុំរបស់ភាគីវិវាទ។

# ៣.កិច្ចដំណើរការនៃការសម្រុះសម្រួលដោះស្រាយវិវាទរបស់ អ.ជ.ក.

## ៣.៤. ការដាក់ពាក្យប្ដឹងទៅសាលាដំបូងជំទាស់នឹងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ

ភាគីពាក់ព័ន្ធ ឬតតិយជន ក៏អាចដាក់ពាក្យបណ្ដឹងទៅសាលាដំបូង ជំទាស់នឹងកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ក្នុងករណី ៖

១-ខ្លឹមសារនៃកំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ ផ្ទុយនឹងបទប្បញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ ឬសណ្ដាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា។

២-កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់តតិយជន។

# សូមអរគុណ!

រក្សាសិទ្ធិដោយ៖
នាយកដ្ឋានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់
នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី